# LONG BEACH UNIFIED SCHOOL DISTRICT

# សំនួរលើកសួរជាញឹកញាប់អំពីការកែប្រែតំបន់គ្រប់គ្រង

1. **តើអ្វីទៅ ហៅថា ការកែប្រែតំបន់គ្រប់គ្រង?**

   ការកែប្រែតំបន់គ្រប់គ្រង គឺជាដំណើរការ ដែលក្រសួងអប់រំ ឱស្រ្ទីត ធ្វើការសម្រេចមើល ដើម្បីបញ្ជាក់ថា ចំនួនប្រជារាស្រ្តនៅតាមតំបន់គ្រប់គ្រងនិមួយៗសម្រាប់ នាយកគណៈកម្មការផ្នែកសិក្សាធិការ គឺពិតជាមានភាពស្មើគ្នាមែន ។ នេះជាការរៀបចំឡើងសម្រាប់ពេលបោះឆ្នោតទៅកាន់នាយកគណៈកម្មការផ្នែកសិក្សាធិការ ។

2. **តើហេតុអ្វីបានជាសំខាន់?**

   របៀប និង កន្លែងគូសព្រំដែនសម្រាប់តំបន់គ្រប់គ្រង គឺអាចប៉ះពាល់ដល់សមត្ថភាពក្នុងសហគមន៍នៅពេលជ្រើសរើសយកអ្នកតំណាងស្របតាមចំណង់ចិត្តរបស់គេ ។ តំបន់គ្រង់គ្រងទាំងអស់សម្រាប់នាយកគណៈកម្មការផ្នែកសិក្សាធិការ គឺត្រូវមានចំនួនប្រជារាស្រ្តស្មើគ្នា ដើម្បីទុកឱ្យសហគមន៍មានឱកាសស្មើគ្នាក្នុងការបោះឆ្នោតជ្រើសរើសយកអ្នកតំណាង ។

3. **តើការកែប្រែតំបន់គ្រប់គ្រង គឺធ្វើទៅកាន់កម្រិតញឹកញាប់ជារបៀបណា?**

   បន្ទាប់ពីមានការរាប់ចំនួនប្រជារាស្រ្ត ដប់ ឆ្នាំម្តង គឺក្រសួងអប់រំ ឱស្រ្ទីត នឹងទទួលការតម្រូវឱ្យធ្វើការសើរើអំពីលទ្ធផលនៃចំនួនប្រជារាស្រ្ត ដើម្បីសម្រេចថា តើកៅអីបោះឆ្នោត គឺនៅតែស្របតាមច្បាប់ មែនទេ និង ធ្វើការកែប្រែតាមសេចក្តីចាំបាច់ ដើម្បីបញ្ជាក់ថាតំបន់គ្រប់គ្រងសម្រាប់នាយកគណៈកម្មការផ្នែកសិក្សាធិការ គឺពិតជាមានចំនួនប្រជារាស្រ្តស្មើគ្នាមែន ។

4. **តើដំណើរការប្រើពេលវេលាសម្រាប់កែប្រែតំបន់គ្រប់គ្រងនៅក្នុងឆ្នាំនេះ គឺនឹងមានដូចម្តេច?**

   - ខែកញ្ញា ទី14 — កិច្ចប្រជុំគណៈកម្មការសាលារៀនៈ ការណែនាំបង្ហាញគម្រោងកែប្រែតំបន់គ្រប់គ្រង
   - ខែកញ្ញា — ការបានទទួលលទ្ធផលពីការរាប់ចំនួនប្រជារាស្រ្តក្នុងឆ្នាំ ២០២០ និង ការស្ទង់មើលចំនួនប្រជារាស្រ្តនៅតាមតំបនៈគ្រប់គ្រងនិមួយៗនៃគណៈកម្មការសាលារៀន<br>ការរៀបចំប្រើ គេហទំព័រ
   - ខែតុលា ទី6 — កិច្ចប្រជុំគណៈកម្មការសាលារៀនៈ ការលើកបង្ហាញអំពីចំនួនប្រជារាស្រ្តថ្មី<br>ការស្ទង់វាស់មតិទៅកាន់សហគមន៍ និង ការពិគ្រោះអំពីលក្ខណសម្រាប់
   - ខែតុលា — ការបង្កើតផែនទីថ្មី ស្របតាមការកែប្រែនៅតាមតំបន់បោះឆ្នោតសម្រាប់គណៈកម្មការសាលារៀន ដោយទទួលមកវិញជាមតិពីសមាជិកគណៈកម្មការ និង សហគមន៍
   - ខែតុលា ថ្ងៃទី20 — កិច្ចប្រជុំគណៈកម្មការសាលារៀនៈ ការលើកបង្ហាញផែនទី ដែលបានគូសព្រាង
   - ខែវិច្ឆិកា ទី3 — កិច្ចប្រជុំគណៈកម្មការសាលារៀនៈ ការលើកបង្ហាញផែនទី ដែលបានគូសព្រាង (បើចាំបាច់)
   - ខែវិច្ឆិកា — កិច្ចប្រជុំជាមួយសហគមន៍អំពីការសើរើមើលផែនទី ដែលបានគូសព្រាង
   - ខែធ្នូ ទី1 — កិច្ចប្រជុំគណៈកម្មការសាលារៀនៈ គណៈកម្មការសាលារៀនធ្វើការទទួលស្គាល់មកលើផែនទី

5. **សព្វថ្ងៃ តើអ្នកណាជាសមាជិកគណៈកម្មការសាលារៀនប្រចាំ LBUSD និង តើម្នាក់ៗធ្វើជាអ្នកតំណាងក្នុងតំបន់គ្រប់គ្រងណា?**

   ក្នុងពេលឥឡូវនេះ គឺមានៈ

   - Megan Kerr - LBUSD Trustee District 1 - តំបន់ មួយ
   - Erik Miller - LBUSD Trustee District 2 - តំបន់ ពីរ
   - Dr. Juan Benitez - LBUSD Trustee District 3 - តំបន់ បី
   - Douglas Otto - LBUSD Trustee District 4 - តំបន់ បួន
   - Diana Craighead - LBUSD Trustee District 5 - តំបន់ ប្រាំ

ប្រជារាស្ត្រធ្វើការបោះឆ្នោតជ្រើសរើសយកសមាជិកគណៈកម្មការសាលារៀនចំនួន ប្រាំ នាក់ ស្របតាមតំបន់គ្រប់គ្រង ដើម្បីកាន់មុខងារ បួន ឆ្នាំ សម្រាប់មួយនីតិកាល ។

6. **តើការកែប្រែតំបន់គ្រប់គ្រងមានភាពប៉ះពាល់មកលើព្រំដែនសាលារៀន ដែរ ឬ ទេ?**
គ្មានទេ ។ ដំណើរការកែប្រែតំបន់គ្រប់គ្រង គឺគ្មានអ្វីប៉ះពាល់ដល់ព្រំដែនសាលារៀននោះទេ ។ ការកែប្រែតំបន់គ្រប់គ្រងគ្រាន់តែប៉ះពាល់មកលើតំបន់សម្រាប់នាយកគណៈកម្មការផ្នែកសិក្សាធិការប៉ុណ្ណោះសម្រាប់ឱ្យមានជាចំនួនប្រជារាស្ត្របោះឆ្នោតស្មើគ្នា ។

7. **តើមានគម្រោងតាមវិធីណាសម្រាប់ទាក់ទាញទំនាក់ទំនងពីសហគមន៍?**
LBUSD កំពុងរៀបគម្រោងធ្វើទំនាក់ទំនងជាបន្តបន្ទាប់ទៅកាន់សហគមន៍ ។ លើកទីមួយ គឺក្នុងកិច្ចប្រជុំនាយកគណៈកម្មការផ្នែកសិក្សាធិការនៅថ្ងៃទី14 ខែកញ្ញា ហើយនឹងមានការលើកបង្ហាញជាបន្ថែមនៅតាមគម្រោងគ្រោងទុកដូចតទៅ:

- ការស្ទង់វាស់មតិ - ការយកចិត្តទុកដាក់ពីសហគមន៍ (ខែកញ្ញា)
- គេហទំព័រ រៀបរាប់តែអំពីការកែប្រែតំបន់គ្រប់គ្រង (ខែកញ្ញា)
- ព័ត៌មានថ្មីៗ និង ការជ្រើសរើសគូសផែនទីសម្រាប់បង្ហាញក្នុងកិច្ចប្រជុំនាយកគណៈកម្មការផ្នែកសិក្សាធិការ (ខែតុលា & វិច្ឆិកា)
- កិច្ចប្រជុំជាមួយសហគមន៍ (ខែវិច្ឆិកា)

ព័ត៌មានបន្ថែមអំពីការបង្កើតទំនាក់ទំនង គឺនឹងចុះផ្សាយទាន់ពេលនៅក្នុង គេហទំព័រ LBUSD Redistricting Webpage (LINK) ឬ www.lbschools.net > Offices > Board of Education > Redistricting

8. **តើអ្វីទៅជាការយកចិត្តទុកដាក់ពីសហគមន៍?**
ការយកចិត្តទុកដាក់ពីសហគមន៍ គឺជាកត្តាដ៏សំខាន់សម្រាប់ការកែប្រែតំបន់គ្រប់គ្រង ។ ការយកចិត្តទុកដាក់ពីសហគមន៍ គឺជាទីសង្កាត់ សហគមន៍ ឬ ក្រុមប្រជារាស្ត្រ ដែលមានបំណងដូចគ្នាមកលើច្បាប់ផ្សេងៗ ដែលជួយចម្រើនដល់តំបន់គ្រប់គ្រងមួយកន្លែង ។ មធ្យោបាយម្យ៉ាងផ្សេងសម្រាប់យល់ដឹងអំពីការយកចិត្តទុកដាក់ពីសហគមន៍ គឺគ្រាន់តែស្តាប់សហគមន៍ធ្វើការរៀបរាប់អំពីបទពិសោធន៍ ដែលមនុស្សជិតខាងរបស់ពួកគេមានបញ្ហាអ្វីដូចតែគ្នា និង អ្វីផ្សេងទៀត ដែលធ្វើឱ្យពួកគេមានលក្ខណៈពិសេសបើប្រៀបធៀបទៅជាមួយសហគមន៍ផ្សេងៗស្ថិតនៅក្បែរ ។

9. **តើហេតុអ្វីបានជាការយកចិត្តទុកដាក់ពីសហគមន៍មានសារសំខាន់ម្លេះមកលើដំណើរការកែប្រែតំបន់គ្រប់គ្រង?**

ការរក្សាទុកការយកចិត្តទុកដាក់ពីសហគមន៍ឱ្យនៅរួមគ្នា គឺជាគោលការណ៍សំខាន់សម្រាប់ការកែប្រែតំបន់គ្រប់គ្រង ។ សមាជិកក្នុងសហគមន៍អាចចាត់ទុកសហគមន៍របស់ពួកគេតាមរយៈលើកបង្ហាញបទពិសោធន៍របស់ពួកគេ និង ធ្វើការរៀបរាប់អំពីបញ្ហាខ្វល់ខ្វាយផ្សេងៗរបស់ពួកគេទៅកាន់អ្នកបង្កើតច្បាប់ ។

ក្រុមដូច្នេះ គឺរាប់បញ្ចូលទាំង (គ្មានកម្រិតទេ) ក្រុម ដែលមានវប្បធម៌ ឬ ប្រវត្តិសាស្ត្រភ្ជាប់គ្នា ជាប់ពូជសាសន៍ ឬ កាន់ជំនឿសាសនាដូចគ្នា រស់នៅក្នុងទីសង្កាត់រួមគ្នា ឬ មានការសម្លឹងគិតដូចតែគ្នាអំពីអនាគតនៃសហគមន៍ ។

មតិពីលោកអ្នក គឺត្រូវការទទួលយក ដើម្បីជួយសម្រេចអំពីការគូសព្រំដែននៅតាមតំបន់គ្រប់គ្រងសម្រាប់នាយកគណៈកម្មការផ្នែកសិក្សាធិការ ។ សូមប្រើសម្លេងរបស់លោកអ្នកសម្រាប់បង្កើតជាបញ្ជី "Communities of Interest" ឬ "COI" ដែលអាចជួយរៀបជាដំណើរការបានមកលើការបណ្តុះបណ្តាលតំបន់គ្រប់គ្រងសម្រាប់នាយកគណៈកម្មការផ្នែកសិក្សាធិការរបស់លោកអ្នក ។

LBUSD ស្នើសុំដល់ប្រជារាស្ត្រនៃក្រសួងអប់រំ ឱស្ទ្រីគ ឆ្លើយបំពេញសំនួរស្ទង់វាស់មតិជា ពីរ ចំណែក ដូចតទៅ:

- តើអ្វីទៅបង្កើតជាភាពស្និទ្ធស្នាលរួមគ្នានៅក្នុងសហគមន៍របស់លោកអ្នក ឬ បង្កើតជាអត្តសញ្ញាណស្រដៀងគ្នា?
- តើសហគមន៍របស់លោកអ្នកស្ថិតនៅទីណា?

សំនួរស្ទង់វាស់មតិ គឺអាចស្វែងរកឃើញនៅតាម គេហទំព័រ LBUSD Redistricting Webpage (LINK) ឬ www.lbschools.net > Offices > Board of Education > Redistricting

10. **តើសហគមន៍អាចចូលរួមចំណែកបានតាមវិធីណា?**

កិច្ចការមួយដ៏សំខាន់អំពីដំណើរការកែប្រែតំបន់គ្រប់គ្រង គឺសុំឱ្យសហគមន៍លើកបង្ហាញអំពីការយល់ឃើញរបស់គេមកលើសំនួរស្ទង់វាស់មតិជា ពីរ ចំណែក ដែលអាចស្វែងរកឃើញនៅតាម គេហទំព័រ LBUSD Redistricting Webpage ។

មតិពីលោកអ្នក គឺត្រូវការទទួលយក ដើម្បីជួយសម្រេចអំពីការគូសព្រំដែននៅតាមតំបន់គ្រប់គ្រងសម្រាប់នាយកគណៈកម្មការផ្នែកសិក្សាធិការ ។ សូមប្រើសម្លេងរបស់លោកអ្នកសម្រាប់បង្កើតជាបញ្ជី "Communities of Interest" ឬ "COI" ដែលអាចជួយរៀបជាដំណើរការបានមកលើការបណ្ដុះបណ្ដាលតំបន់គ្រប់គ្រងសម្រាប់នាយកគណៈកម្មការផ្នែកសិក្សាធិការរបស់លោកអ្នក ។

ព័ត៌មានបន្ថែមអំពីការយកចិត្តទុកដាក់ពីសហគមន៍ គឺអាចស្វែងរកឃើញក្នុងទំព័រ FAQ ។ បន្ថែមទៅទៀត សំនួរស្ទង់វាស់មតិផ្ទាល់នោះឯង គឺមានបង្ហាញជាអត្ថន័យ និង ព័ត៌មានពន្យល់អំពីការយកចិត្តទុកដាក់ពីសហគមន៍ ។

សូមចូលពិនិត្យនៅតាម គេហទំព័រ LBSUD Redistricting Webpage (LINK) ដើម្បីទទួលព័ត៌មានថ្មីៗ ឬ www.lbschools.net > Offices > Board of Education > Redistricting

11. **តើខ្ញុំអាចស្វែងរកព័ត៌មានបន្ថែមអំពីដំណើរការកែប្រែតំបន់គ្រប់គ្រងក្នុង LBUSD នៅកន្លែងណា?**

សូមចូលពិនិត្យនៅតាម គេហទំព័រ LBUSD Redistricting Webpage (LINK) ដើម្បីទទួលព័ត៌មានថ្មីៗ ឬ www.lbschools.net > Offices > Board of Education > Redistricting



ត្រូវបានកែសម្រួលនៅ 10/22/21

1. **តើមានអ្វីថ្មីអំពីដំណើរការសម្រាប់ការកែប្រែតំបន់គ្រប់គ្រងនៅក្នុង LBUSD?**
ផែនទីគូសព្រាងទុក! គណៈកម្មការសាលារៀន LBUSD បានសុំឱ្យមានការគូសផែនទីព្រាងទុក ដើម្បីធ្វើការគិតគូរមើលអំពីតំបន់គ្រប់គ្រងថ្មីសម្រាប់សមាជិកគណៈកម្មការសាលារៀន ។ ផែនទីគូសព្រាងទុកទាំងអស់ត្រូវបានតាំងបង្ហាញនៅក្នុង គេហទំព័រ LBUSD Redistricting (lbschools.net/redistricting) ។ យើងសូមអញ្ជើញលោកអ្នកចូលរួមបើកមើលអំពីផែនទី និង ផ្តល់ជាមតិមកវិញ ។




2. **តើមានការធ្វើស្ទង់វាស់មតិអ្វីទេ ដែលខ្ញុំអាចដាក់ពាក្យផ្តាំផ្ញើបានមកលើផែនទី ដែលបានគូសព្រាងទុកមក?**
ពិតណាស់! មានសំនួរស្ទង់វាស់មតិថ្មីមួយត្រូវបានដាក់បញ្ចូលនៅ 10/20/21 ដែលសួរអំពីការបង្ហាញជាពាក្យផ្តាំផ្ញើមកលើផែនទី ដែលបានគូសព្រាងទុកមក ។ សំនួរស្ទង់វាស់មតិថ្មីនេះ គឺអាចរកឃើញបាននៅតាម lbschools.net/redistricting ក្នុងគេហទំព័រ LBUSD Redistricting ។




3. **ស្ថិតនៅក្រោមផែនទីនិមួយៗ ដែលបានគូសព្រាងទុក តើមានសាលារៀនណាខ្លះស្ថិតនៅតាមតំបន់គ្រប់គ្រងនៃគណៈកម្មការសាលារៀន?**
ជាបឋម សូមធ្វើការរំលឹកថា ការគូសផែនទីឡើងវិញ គឺនឹងគ្មានផ្លាស់ប្តូរអ្វីទេទៅកាន់ព្រំដែនសាលារៀន ។ ការកែប្រែតំបន់គ្រប់គ្រង គឺគ្រាន់តែប៉ះពាល់មកលើតំបន់គ្រប់គ្រងនៃគណៈកម្មការសាលារៀនប៉ុណ្ណោះសម្រាប់ប្រជារាស្ត្របោះឆ្នោតមានជាតំណាងភាពស្មើគ្នា ។ ដើម្បីធ្វើការប្រៀបធៀបមើលអំពីតំណាងភាពសម្រាប់គណៈកម្មការសាលារៀននៅតាមផែនទីថ្មីនិមួយៗ គឺសូមចុចយក click here ។